ការបិទសាលានិងពន្យារបន្តរហូតដល់ថ្ងៃថ្មី៣ខែឧសភា យ៉ាងឆាប់។
ការបិទសាលាទាំងអស់នៅក្នុងក្រសួងអប់រំឡុងប៊ីចនឹងពន្យារបន្តរហូតដល់ថ្ងៃទី៣ខែឧសភាយ៉ាងឆាប់ ដោយសារស្ថានភាពវីរុសក្ររ៉ូណា។ សាលារៀនពីមុនបានគ្រោងបើកទ្វារវិញនៅថ្ងៃទី២០ខែមេសា។ សាលារៀនអាចបើកទ្វារវិញនៅថ្ងៃទី៤ ខែឧសភា ប៉ុន្តែការពន្យារបន្ថែមទៀតអាចនឹងមានឡើង។

ក្រុមអ្នកដឹកនាំក្រសួងអប់រំបានសម្រេចបន្ថែមថ្ងៃបិទសាលាបន្ទាប់ពីបានធ្វើការពីគ្រោះយ៉ាងល្អិតល្អន់ជាមួយអង្គការជាដៃគូផ្សេងៗ មានរួមទាំងការិយាល័យអប់រំប្រចាំខោនធីឡសអ៊ិនជើលេស។ កត្តាដែលសំខាន់ជាងគេក្នុងការសម្រេចនេះគឺដើម្បីសុខភាពដល់អ្នករាល់គ្នានៅក្នុងសហគមន៍សាលារៀននិងមហាជនទូទៅ។

នៅក្នុងរយៈដែលសាលាបិទនេះ សាលារៀននឹងបន្តចែកអាហារនិងផ្តល់ឱកាសសិក្សានៅផ្ទះ។ នៅល្ងាចថ្ងៃច័ន្ទទី២៣មិនា ក្រសួងអប់រំឡុងប៊ីចLBUSD នឹងផ្ញើព័ត៌មាននៃការសិក្សានៅផ្ទះ សម្រាប់ការសិក្សាទូទៅ និងសិស្សក្នុងកម្មវិធីអប់រំពិសេស ហើយនិងក្រុមគ្រួសារសិស្ស។ កម្មវិធីនៃការសិក្សានៅផ្ទះនេះគឺសម្រាប់ក្នុងកំឡុងរយៈពេលពីថ្ងៃច័ន្ទ ទី២៣មិនា ទៅដល់ថ្ងៃព្រហស្បតិ៍ ទី៩មេសា។ មេរៀននិងធនធានសិក្សាត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់កម្មវិធី ការសិក្សាជាបន្ត នៅក្នុងកំរិតថ្នាក់របស់សិស្ស រហូតដល់ថ្ងៃទី៩មេសា(ដែលគឺជាថ្ងៃមុនថ្ងៃបុណ្យឈប់សម្រាកនៅថ្ងៃទី១០មេសា និងការឈប់សម្រាកនិទាឃរដូវមួយសប្តាហ៍ក្នុងសប្តាហ៍បន្ទាប់)។ កម្មវិធីសិក្សានៅផ្ទះនេះនឹងមិនមានកត់ជាពិន្ទុទេ។

ដូចដែលបានជូនជាដំណឹងកាលពីម្សិលមិញមក ចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី២៣មិនា សេវាកម្មចែកអាហារនៅសាលានឹងបន្តចែកឱ្យពីម៉ោង៨ទៅ៩ព្រឹកសម្រាប់អាហារព្រឹក និងពីម៉ោង១១:៣០ព្រឹកទៅដល់ម៉ោង១:00 រសៀលសម្រាប់អាហារថ្ងៃត្រង់នៅគ្រប់ សាលារៀនទាំងអស់លើកលែងតែសាលា Beach/Reid, Browning, CAMS, Lowell, Millikan, Naples, PAAL, Renaissance, Sato and Stanford ។ សាលារៀនទាំងនោះឈប់ផ្តល់សេវាចែកអាហារទៀតហើយនៅក្នុងរយៈពេលដែលសាលារៀនបិទទ្វារ។ ចាប់ផ្តើមពីថ្ងៃអង្គារទី២៤មិនា សាលារៀនដែលនៅចែកអាហារនឹងប្តូរទៅចែកតែមួយពេលប៉ុណ្ណោះ គឺពីម៉ោង១១:៣០ព្រឹកទៅដល់ម៉ោង១រសៀល។ នៅពេលនោះ សិស្សនឹងបានទទួលអាហារថ្ងៃត្រង់ ហើយនិងអាហារព្រឹកសម្រាប់ពេលព្រឹកនៅថ្ងៃស្អែកផងដែរ។ សិស្សដែលរៀននៅសាលាទាំងឡាយដែលឈប់ផ្តល់សេវាចែកអាហារអាចទៅយកអាហារនៅសាលាដែលនៅជិតផ្ទះជាងគេ។ រកមើលផែនទីសាលារៀនរបស់ LBUSD នៅ lbschools.net រួចចុចលើពាក្យ ABOUT បន្ទាប់មកចុចលើពាក្យ Map.

បើសិនជាអ្នកត្រូវការកុំព្យូទ័រ ក្រុមប៊ុក Chromebook ឧបករណ៍នេះនឹងមានឱ្យប្រើចាប់ពីថ្ងៃពុធទី២៥មិនាទៅ។ សាលារៀនក៏អាចផ្តល់ព័ត៌មានអំពីការមានលទ្ធភាពប្រើប្រាស់អ៊ិនធើនែតនៅផ្ទះផងដែរ ចំពោះគ្រួសារណាដែល មិនមានអ៊ិនធើនែតនៅផ្ទះ។ ព័ត៌មានថែមទៀតនឹងផ្តល់ជូននៅសប្តាហ៍ក្រោយ។ សម្ភារៈសិក្សានៅផ្ទះនឹងមានផ្តល់ជាក្រដាសដល់គ្រួសារណាដែលត្រូវការ ចាប់ផ្តើមនៅថ្ងៃអង្គារ ទី២៤មិនា។

សូមតាមដានមើលព័ត៌មានបច្ចុប្បន្នភាពនៅលើគេហទំព័រ LBUSD នៅ lbschools.net ។ ថែមពីនោះទៀត លោកអ្នកអាចរកមើលធនធា ផ្សេងៗ មានរួមទាំងការប្រកាសផ្សាយដំណឹងកន្លងៗមក នៅគេហទំព័រព័ត៌មានវីរុសក្ររ៉ូណារបស់ LBUSD នៅ lbschools.net/coronavirus ។ ការជូនដំណឹងនឹងបន្តផ្តល់ឱយតាមរយៈគេហទំព័រសាលារៀននីមួយៗ អ៊ីមែល សារសារទូរស័ព្ទ និងប្រព័ន្ធបណ្តាញសង្គម នៅថ្ងៃមុខជាបន្តបន្ទាប់ទៅនេះ។